តុលាការខេត្តបាត់ដំបង

រឿងព្រហ្មទណ្ឌ

លេខ ៨២១ ចុះថ្ងៃទី ១១

ខែ វិច្ឆិកា ឆ្នាំ ២០០៤

សាលក្រមព្រហ្មទណ្ឌ

លេខ ៨២ "៧" ចុះថ្ងៃទី ១១

ខែ មេសា ឆ្នាំ ២០០៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ

លោក [redacted] ចៅក្រមតុលាការខេត្តបាត់ដំបង

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងតុលាការខេត្តបាត់ដំបង

ក្រឡាបញ្ជីសវនាការ

ក. [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៨២១ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទ :

១-ឈ្មោះ [redacted] ណារ៉ូ ភេទប្រុស អាយុ ៤៦ ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីរត់ឡានឈ្នួល មានទីកន្លែងកំណើតនៅភូមិវត្តកណ្តាល ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។ មានកំរិតវប្បធម៌ ថ្នាក់ទី ៣ ចាស់ កាន់សាសនាព្រះពុទ្ធ មាន[redacted] ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ [redacted] រ៉ា " រ " មានកូន ០៥ នាក់ មានឪពុកឈ្មោះ [redacted] " ស " មានម្តាយឈ្មោះ [redacted] " ស " ទោសពីមុន គ្មាន ។

២- ឈ្មោះ [redacted] រ៉ា ភេទស្រី អាយុ ៤១ ឆ្នាំ ជាតិឥស្លាម សញ្ជាតិខ្មែរ របររកស៊ី គ្មាន កើតនៅភូមិនរា ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង កំរិតវប្បធម៌ មិនចេះអក្សរ កាន់សាសនាមហាម៉ាត់ [redacted] សព្វថ្ងៃភូមិនរា [redacted] ខេត្តបាត់ដំបង មានប្តីឈ្មោះ [redacted] ណារ៉ូ " រ " មានកូន ០៥ នាក់ ឪពុកឈ្មោះ [redacted] ស៊ីម " ស " ម្តាយឈ្មោះ [redacted] សារី " ស " ទោសពីមុនធ្លាប់មានទោសព្យួរ ១០ ខែ ។

៣- ឈ្មោះ [redacted] រ៉ាហ៊ីន ភេទស្រី អាយុ ១៩ ឆ្នាំ ជនជាតិខ្មែរឥស្លាម របររកស៊ី គ្មាន កើតនៅភូមិនរា [redacted] ខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៩ ថ្មី កាន់សាសនាមហាម៉ាត់ មានទីលំនៅសព្វថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] ណារ៉ូ " រ " ម្តាយឈ្មោះ [redacted] " រ " ទោសពីមុនគ្មាន ។

៤- ឈ្មោះ [redacted] រ៉ាហ៊ី ភេទស្រី អាយុ ២២ ឆ្នាំ ជនជាតិខ្មែរឥស្លាម របររកស៊ី គ្មាន កើតនៅភូមិ ...ត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៩ ថ្មី កាន់សាសនាមហាម៉ាត់ មានទីលំនៅសព្វនរា ឃុំនរា [redacted] ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] ណារ៉ូ ថ្ងៃភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង " រ " ម្តាយឈ្មោះ [redacted] រ៉ា " រ " ទោសពីមុនគ្មាន

៥- ឈ្មោះ [redacted] ឈាន ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី លក់គ្រឿងក្មេង កើតនៅភូមិព្រៃដាច់ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌ គ្មាន កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិចំកា[redacted] ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] ឈាង " រ " ម្តាយ ឈ្មោះ [redacted] " រ " ទោសពីមុនគ្មាន ។

៦- ឈ្មោះ [redacted] ជាស៊ី ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី គ្មាន កើតនៅភូមិអូរចារ ឃុំជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៨ ថ្មី កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ[redacted]យប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្តីឈ្មោ[redacted] " រ " មានកូន ០៣ នាក់ មានឪពុកឈ្មោះ[redacted] " រ " ម្តាយ ឈ្មោះ [redacted] " រ " ទោសពីមុនគ្មាន ។

៧- ឈ្មោះ [redacted] វណ្ណា ហៅ សេក ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី ជាងមាស និងរត់ម៉ូតូឌុប កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កំរិតវប្បធម៌ សញ្ញាប័ត្រ បឋមភូមិ កាន់សាស[redacted]មិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ [redacted] ជាស៊ី " រ " មានកូន ០៣ នាក់ មានឪពុកឈ្មោ[redacted]កាំង " រ " ម្តាឈ្មោះ [redacted] រិទ្ធិ " រ " ទោសពីមុនគ្មាន ។

៨- ឈ្មោះ [redacted] ទេវី ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី រៀនកែសម្ផស្ស កើតនៅភូមិចំការសំរោង ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៣ ថ្មី កាន់សាសនា ព្រះពុទ្ធ ទីលំ[redacted] ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] វិត " ស " ម្តាយ ឈ្មោះ[redacted]សារី " ស " ទោសពីមុនគ្មាន ។

៩- ឈ្មោះ [redacted] ឌី ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី នៅផ្ទះ កើតនៅភូមិផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង កំរិតវប្បធម៌ អត់ចេះអក្សរ កាន់សាសនា ព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ [redacted]ាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោ[redacted]វិត " ស " ម្តាយ ឈ្មោះ[redacted] សារី " ស " ទោសពីមុនគ្មាន ។

១០- ឈ្មោ[redacted]ឫ ភេទប្រុស អាយុ ១៧ ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី ជាងម៉ាស៊ីន កើតនៅភូមិ ផ្កាស្លា ឃុំចំការសំរោង ទីរួមខេត្តបាត់ដំបង កំរិតវប្បធម៌ ថ្នាក់ទី ៥ ថ្មី កាន់សាសនា ព្រះពុទ្ធ ទីលំនៅ- សព្វថ្ងៃភូមិ[redacted] ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ [redacted] វិត " ស " ម្តាយ ឈ្មោះ[redacted] " ស " ទោសពីមុនគ្មាន ។

ជនជាប់ចោទជាប់ចោទពីបទបង្ករបួសដោយចេតនាមានអាវុធ និងជេរប្រមាថ ប្រព្រឹត្តនៅ- ភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្តន្ទាទោសតាមមាត្រា ៤១ និង ៦៣ នៃច្បាប់ព្រហ្ម- ទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>

- ឈ្មោះ [redacted] ណារ៉ុ ភេទប្រុស អាយុ ៤៦ ឆ្នាំ មានទីលំនៅសព្វថ្ងៃនៅភូមិនរា ឃុំនរា ស្រុក

Scanned with CamScanner

សង្កែ ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនជំនួសមុខប្រពន្ធ និងកូនសុំប្តឹងទាមទារសំណងព្យាបាល និងជម្ងឺចិត្តរួមទាំងការបាត់បង់គ្រឿងអលង្ការរបស់កូនសរុបចំនួន ៧.០០០.០០០៛០០ ( ប្រាំពីរលានរៀលគត់ ) ឯជនល្មើសប្រគល់ជូន-តុលាការសំរេចតាមច្បាប់ ។

- ឈ្មោះ [redacted] ជាស៊ុី ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងព្យាបាល និងជម្ងឺចិត្តសរុបទាំងការបាត់បង់របស់ចំនួន -២.០០០ ដុល្លា ( ពីរពាន់ដុល្លាអាមេរិក ) ចំណែកជនល្មើសសុំអោយតុលាការផ្តន្ទាទោសទៅតាមច្បាប់ ។

- ឈ្មោះ[redacted] វិណ្ណា ហៅ សេក ភេទប្រុស អាយុ ៣៥ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំ បង

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងព្យាបាលរបួស និងជម្ងឺចិត្តសរុបចំនួន ២.០០០ ដុល្លា ( ពីរពាន់ដុល្លាអាមេរិក ) ឯជនល្មើសសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

- ឈ្មោះ[redacted] ទេវី ភេទស្រី អាយុ ២២ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយ-ប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងព្យាបាល សំណងអន្តរាយ និងជម្ងឺចិត្តសរុប ៥.០០០ ដុល្លា ( ប្រាំពាន់ដុល្លាអាមេរិក ) ឯជនល្មើសសុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

- ឈ្មោះ [redacted]ទី ភេទស្រី អាយុ ១៨ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលជម្ងឺចំនួន ៣០.០០០ បាត ( បីម៉ឺនបាតគត់ ) បើគ្មានប្រាក់សងទេ សុំអោយតុលាការផ្តន្ទាទោសតាមច្បាប់ ។

- ឈ្មោះ [redacted]សុខា ភេទស្រី អាយុ ៣២ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិអូរតាគាំ២ ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ខ្លួនសុំសំណូមពរ សុំទាមទារថ្លៃសំណងកិត្តិយស និងសំណងជម្ងឺចិត្តសរុប ១០.០០០.០០០៛០០ ( ដប់លានរៀលគត់ ) ឯជនល្មើសសុំអោយតុលាការធ្វើការឃុំខ្លួន និងសំរេចទៅតាមផ្លូវច្បាប់ ។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៨៦ ដសសព ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង ។

- បានឃើញដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ១០៣២ ពសព្រទ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តបាត់ដំបង ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទ</u>

កាលពីថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៦ វេលាម៉ោង ១០ និង៣០នាទីយប់ មានជនល្មើសពីរក្រុម

ក្រុមទី ១ មានឈ្មោះ :១[redacted]ហៅ ភេទប្រុស .២- [redacted]រ៉ា ភេទស្រី . ៣-[redacted]ហ៊ីន ភេទស្រី .៤[redacted]រ៉ហ៊ី

ភេទស្រី និង[redacted] ណាន ភេទប្រុស . ក្រុមទី២ មានឈ្មោះ :១-[redacted] ជាស៊ុី ហៅ ពៅ ភេទស្រី . ២-[redacted] វណ្ណា ហៅ សេក ភេទប្រុស .៣-[redacted] ទេវី ភេទស្រី .៤-[redacted] ឌី ភេទស្រី និង[redacted] ប៊ូ ភេទប្រុស បានជេរប្រមាថ និងវាយគ្នាទៅវិញទៅមកបណ្តាលអោយរងគ្រោះទាំងសងខាង ។

**ការឆ្លើយសម្ភាសន៍**

- ជនជាប់ចោទ និងជាដើមបណ្តឹងឈ្មោះ [redacted] វណ្ណា បានឆ្លើយថា : កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ៩ ទៅ ១០ យប់ ពេលនោះ ខ្លួនបានទៅហៅក្មួយឈ្មោះ[redacted] ទេវី មកផ្ទះ ព្រោះរៀបចំហូបបាយ ពេលទៅហៅត្រឡប់មកវិញហូបបាយបានពីរម៉ាត់ស្រាប់ តែឈ្មោះ[redacted] ណារ៉ូ ទាញខ្លួនចេញ ហើយវាយខ្លួន និងដៃ ហើយមានបុរសពីរនាក់ទៀតបានវាយខ្លួន និងឃើញឈ្មោះ[redacted] រ៉ា កាន់ដែក- ហើយមានកូនស្រីរបស់គាត់ និងស្រីខារ៉ាអូខេបានមកវាយខ្លួន និងប្រពន្ធ និងក្មួយ ក្រោយមកកូនគាត់បានគប់កែវចូលក្នុងផ្ទះខ្លួនទៀត ពេលនោះខ្លួនមិនបានវាយទៅលើគេវិញទេ ដោយខ្លួនមានឈ្មោះ[redacted] ហ៊ុម និង[redacted] ចាន់ដារ៉ា ជាសាក្សី ព្រោះគាត់នៅជិតផ្ទះខ្លួនដោយគាត់បានចេញមកឃាត់ កន្លងមកមិនធ្លាប់មានទំនាស់អ្វីទេ ។

នៅពេលនេះខ្លួនសុំទាមទារថ្លៃព្យាបាល និងជំងឺចិត្តពី[redacted] ណារ៉ូ ចំនួន ១.០០០.០០០៛០០ ( មួយលានរៀល ) ។

ខាងខ្លួនជាជនរងគ្រោះ មិនចង់ប្តឹងតទៅទៀតទេ គ្រាន់តែសុំថ្លៃព្យាបាលក្មួយខ្លះអោយសមរម្យ គឺចំនួន ២.០០០.០០០៛០០ ( ពីរលានរៀល ) ។

- ជនជាប់ចោទ និងជាដើមបណ្តឹងឈ្មោះ[redacted] ឌី បានឆ្លើយថា : នៅថ្ងៃកើតហេតុថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោងដប់ និងសាមសិបនាទីយប់ ពេលខ្លួនបើកទ្វារចេញស្រាប់តែឈ្មោះ[redacted] រ៉ា និងកូនគាត់ពីរនាក់ទៀត ឈ្មោះ[redacted] ហ៊ិន និង[redacted] ហ៊ី មកជិះលើខ្លួន ហើយវាយខ្លួនត្រូវធ្ងន់ ដោយដេកពេទ្យ ១ ថ្ងៃ នៅគ្លីនិកផ្សារបឹងឈូកពេលចេញមកទៅដេកពេទ្យគ្លីនិកសុខភាព ១ យប់ និងព្យួរសេរ៉ូមនៅផ្ទះ ព្យាបាលអស់- ប្រាក់ប៉ុន្មានខ្លួនមិនដឹង ទេព្រោះបងជាអ្នកចេញប្រាក់ ។

- ជនជាប់ចោទ និងជាដើមបណ្តឹងឈ្មោះ[redacted] ទេវី បានឆ្លើយថា : ព្យាបាលប្អូនសរុបអស់ជាង ១.០០០.០០០៛០០ ( មួយលានរៀល ) ថ្ងៃកើតហេតុខ្លួន កំពុងចងអង្រឹងដេកស្រាប់តែ ពូឈ្មោះ[redacted] ណារ៉ូ ជេរថាអាសេកហ្វែងជេរកូនអញហ្វែងខ្លាំងចេញមក ពេលនោះពូខ្លួនកំពុងហូបបាយ ហើយគាត់ចេញទៅ ឈ្មោះ[redacted] ណារ៉ូ វៃ ខ្លួនក៏បានជួយឃាត់ ដោយខ្លួនមិនបានវៃគេវិញទេ ខ្លួនឃើញឈ្មោះ[redacted] រ៉ា កូនរបស់គាត់ និងស្រីខារ៉ាអូខេមកវាយបងខ្លួន១មិនបានវាយ និងជេរគេទេ ។

នៅថ្ងៃកើតហេតុខ្លួនអង្គុយលេងនៅផ្ទះគេទល់មុខផ្ទះឈ្មោះ រ៉ូ ហើយពូខ្លួនមកហៅអោយហូបបាយ ហើយជេរខ្លួនថាមីគេបាញ់ស្ទើណាបានទៅផ្ទះ ស្រាប់តែឈ្មោះ[redacted] រ៉ា យកបំពង់ទីបបុកធ្លុងមីងខ្លួន- ខ្លួនមិនបានវាយគេវិញទេ ហើយខ្លួនបានទូរសព្ទ័ហៅប៉ូលីសមកពេលកំពុងតែចុចទូរស័ព្ទស្រាប់តែកូនរបស់គាត់ . ក្មួយគាត់ និងស្រីខារ៉ាអូខេមកខ្ទេះមុខ និងជិះលើខ្លួន និងវាយក្បាលខ្លួន ព្យាបាលសរុបជាមួយប្អូនអស់ប្រហែល ២.០០០.០០០៛០០( ពីរលានរៀល) ខ្លួនប្តឹងទារពីឈ្មោះ[redacted] រ៉ា កូនគាត់ . ក្មួយគាត់ និងស្រីខារ៉ាអូខេ ។

- ជនជាប់ចោទ និងជាដើមបណ្តឹងឈ្មោះ[redacted] ណារ៉ូ បានឆ្លើយថា : ថ្ងៃកើតហេតុខ្លួនមកពីរត់- ឡានវិញចូលផ្ទះ ប្រហែលម៉ោង ៩ ល្ងាចឈ្មោះវណ្ណា គេកំពុងអង្គុយផឹកស៊ីនៅខាងមុខផ្ទះខាងខ្លួន១ កំពុងដេកអង្រឹងស្រាប់តែឈ្មោះ វណ្ណា បានជេរថាស្រីខ្លួនថាកូនក្មួយចោល ខ្លួនចេះតែអង្គុយស្តាប់ហើយ ពូនិយាយ- ដដែល១ថាកូនអាហ៊្វឹងបានតែគេចុយ ...ម្តេចខ្លួនបានដើរទៅសួរនាំ គេក៏ជេរខ្លួន និងវាយខ្លួនដោយមិនដឹងថាអ្នកណាវាយខ្លួនទេព្រោះគ្នាច្រើនតែឈ្មោះ[redacted] ប៊ូ ទាញឡក្រវាត់វាយកូនស្រីខ្លួន ។

ខ្ញុំនប្តឹងទាមទារថ្លៃបាត់គ្រឿងអលង្ការកូន ថ្លៃព្យាបាលកូន និងជំងឺចិត្តពីឈ្មោះ វណ្ណា ចំនួន ៧.០០០.០០០៛០០ ( ប្រាំពីរលានរៀល ) ។

តាំងពីកើតហេតុមកខ្ញុំនឈប់នៅទីនោះហើយ គឺនាំប្រពន្ធកូនទៅនៅនរាវិញ ឈប់លក់ដូរទុកដីចោល ។ ខ្ញុំនមិនបានវាយគេទេ គ្រាន់តែទៅជល់គេមកព្រួ កូនស្រីខ្ញុំន និងខាងគេខ្ទាចគ្នាមែន គឺខ្ទាចគ្នា-ទៅវិញទៅមក ខ្ញុំនក៏ចង់បញ្ចប់រឿងដែរ សុំអោយចំនួន ៧០០.០០០៛០០ ( ចិតសិបម៉ឺនរៀល ) ។

- ជនជាប់ចោទឈ្មោះ [redacted] ប៊ូ បានឆ្លើយថា : ខ្ញុំនមិនបានវាយគេទេគ្រាន់តែបានជួយឃាត់ ។

- ជនជាប់ចោទ និងជាដើមបណ្តឹងឈ្មោះ [redacted] ផាស៊ី បានឆ្លើយថា : ពេលប្តីមកពីរត់ម៉ូតូឌុប-ខ្ញុំនរៀបបាយអោយគាត់ហូប មិនទាន់បានហូបបាយផង ស្រាប់តែកូនរបស់គាត់ និងគាត់មកអូសទាញប្តីខ្ញុំនទៅ ពេលនោះខ្ញុំនចេញមកកូនស្រីរបស់គាត់ ២ នាក់ និងស្រីខារ៉ាអូខេបានចាប់ខ្ញុំនវាយ ដោយខ្ញុំនមិនបានវ៉ៃគេវិញទេ កន្លងមកមិនធ្លាប់មានទំនាស់គ្នាទេ នៅពេលនេះខ្ញុំនប្តឹងទារពីឈ្មោះ [redacted] រ៉ា ចំនួន ៧.០០០.០០០៛០០ ( ប្រាំពីរលានរៀល ) ។

តាំងពីមានទំនាស់មកមិនដែលមានទំនាស់អ្វី និងគ្នាទៀតទេ ។

- សាក្សីឈ្មោះ [redacted] ចាន់ដារ៉ា បានឆ្លើយថា : នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ១០ យប់ ពេលខ្ញុំនកំពុងដេកស្រាប់តែ ឮសំលេងឈ្លោះគ្នា ហើយខ្ញុំនបានចេញមកឃាត់ពេលនោះឃើញប្រតាយប្រតប់គ្នាទៅវិញទៅមក មានជំបងមានគុបកែវឈ្មោះ [redacted] ឌី ខ្ញុំនឃើញចេញឈាមមុខមិនដឹងត្រូវ នឹងអ្វីទេ ខាងក្រុ[redacted]ណារ៉ូ ដូចមិនឃើញមានរបួសអ្វីទេ ខ្ញុំនមិនដឹងគេឈ្លោះគ្នារឿងអ្វីទេ ឈ្លោះគ្នាប្រហែលកន្លះម៉ោង មួយម៉ោងក្រោយទើបមានសមត្ថកិច្ចចុះទៅ ២ នាក់ ក្រោយកើតឈ្លោះ [redacted] ឌី ត្រូវដឹកទៅមន្ទីរពេទ្យ ។

ខ្ញុំនមិនដឹងថាគ្រួសារទាំងពីរធ្លាប់មានទំនាស់គ្នា រឺអត់ទេ ថ្ងៃកើតហេតុមិនដឹងថាអ្នកណាជេរអ្នកណាមុនទេ គ្រាន់តែខ្ញុំន ឮខាង[redacted]ណារ៉ូ ជេរថាហ្វែងមិនបានខ្ញុំកញ្ចះ ឮសូរតែប៉ុណ្ណឹងខ្ញុំនក៏ឃាត់ បើកទា-របងមុនដំបូង ឃើញប្រតាយគ្នាកៀនពាងទឹក មិនដឹងថាអ្នកណាវាយអ្នកណាមុនទេព្រោះពេលនោះងងឹត គ្រាន់តែឃើញស្រី១ ៣-៤ នាក់ ជិះលើភាគីខាង [redacted] វណ្ណា ខាងឈ្មោះ [redacted] វណ្ណា មិនឃើញមានកាន់អ្វីទេ ឃើញតែឈរអោបដៃ ពេលស្ងាត់ហើយ ភាគីខាង [redacted] ណារ៉ូ ដើរទៅផ្ទះឃើញកាន់កែវក៏គុបកែវចូលផ្ទះ [redacted] វណ្ណា ពេលនោះឃើញ [redacted] ប៊ូ កាន់ខ្សែក្រវ៉ាត់មែន តែមិនបានឃើញវាយអ្នកណាទេ ។

- សាក្សីឈ្មោះ [redacted] ហ៊ុម បានឆ្លើយថា : នៅថ្ងៃកើតហេតុខ្ញុំន ឮ សូរមាត់ឈ្លោះប្រកែកគ្នាក៏ចេញទៅមើលឃើញភាគីទាំងពីរឈ្លោះប្រកែកគ្នា និងប្រតាយប្រតប់គ្នា និងជេរប្រមាថគ្នាទៅវិញទៅមក ខ្ញុំនក៏ឃាត់ហើយក៏បែកគ្នា ឃើញភាគី[redacted]ណារ៉ូ គុបកែវចូលផ្ទះ [redacted] វណ្ណា កន្លងមកភាគីទាំងពីរមិនដឹងថាមាន-ទំនាស់អ្វី និងគ្នាទេ ។

ពេលកើតហេតុដំបូងខ្ញុំននៅក្នុងផ្ទះ ឮសូរជេរគ្នា តែមិនដឹងអ្នកណាជេរអ្នកណាមុនទេ គឺឮតែមាត់ស្រី១ជេរនូវពាក្យអាក្រក់ តែមិនចាំពាក្យទេព្រោះយូរហើយ ចាំតែពាក្យម៉ែងហង១ ខ្លាំងអី ពេលប្រតាយប្រតប់គ្នា ឃើញខាង [redacted] ណារ៉ូ មានគ្នាច្រើនជាង ឃើញ [redacted] ឌី មានរបួស ដោយឈ្មោ[redacted]រ៉ា វាយ ពេលប្រតាយប្រតប់ ឃើញខាង [redacted]ណារ៉ូ កាន់ដំបងក្រោយកើតហេតុឃើញខាង [redacted] ណារ៉ូ គុបកែវចូលទៅមុខផ្ទះ [redacted] វណ្ណា មិនបានឃើញអ្នកណាត្រូវរបួសទេ ឈ្លោះគ្នាប្រហែល ២០ នាទី ។

- បានអានចំលើយចុងចោទឈ្មោះ [redacted] រ៉ា
- បានអានចំលើយរបស់ឈ្មោះ វ៉ុទ្បី
- បានអានវិញ្ញាបនប័ត្រពេទ្យរបស់ឈ្មោះ [redacted] ទើ
- បានអានវិញ្ញាបនប័ត្រពេទ្យរបស់ឈ្មោះ [redacted] ផាស៊ី

Scanned with CamScanner

- បានអានវិញ្ញាបនប័ត្រពេទ្យរបស់ឈ្មោះ [redacted] ឌី

សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ណារ៉ុំ ភេទប្រុស អាយុ ៤៦ ឆ្នាំ ( មានសារ៉េតា ) . [redacted] រ៉ា ភេទស្រី អាយុ ៤១ ឆ្នាំ ( មានសារ៉េតា ) [redacted] រ៉ហ៊ួន ភេទស្រី អាយុ ១៩ ឆ្នាំ ( មានសារ៉េតា ) [redacted] រ៉ហ៊ី ភេទស្រី អាយុ ២២ ឆ្នាំ ( មានសារ៉េតា ) , [redacted] ឈាន ភេទស្រី អាយុ ១៩ ឆ្នាំ ( មានសារ៉េតា ) . [redacted] ជាស៊ី ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ ( មានសារ៉េតា ) [redacted] វណ្ណា ហៅ សេក ភេទប្រុស អាយុ ៣៥ ឆ្នាំ ( មានសារ៉េតា ) [redacted] ទេវី ភេទស្រី អាយុ ២២ ឆ្នាំ ( មានសារ៉េតា ) [redacted] ឌី ភេទស្រី អាយុ ១៨ ឆ្នាំ ( មានសារ៉េតា ) និងឈ្មោះ [redacted] បូ ភេទប្រុស អាយុ ១៧ ឆ្នាំ ( មានសារ៉េតា ) ពីបទបង្ករបួសដោយចេតនាមានអាវុធ និងជេរ ប្រមាថប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងអោយផ្តន្ទាទោសតាមមាត្រា ៤១ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល សូមរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៨៦ ដសសព ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដដែល និងសូមលោកចៅក្រមកំណត់ទោសតាមច្បាប់ ។

សំណូមពររបស់ជនជាប់ចោទឈ្មោះ [redacted] ណារ៉ុំ . [redacted] វណ្ណា . [redacted] ជាស៊ី [redacted] ទេវី . [redacted] បូ និងឈ្មោះ [redacted] ឌី សុំអោយតុលាការលើកលែងទោស ។

ក្រោយពីបានស្តាប់

- ចម្លើយរបស់ជនជាប់ចោទ និងជាដើមបណ្តឹង
- ចម្លើយសាក្សី
- ការអានចម្លើយជនជាប់ចោទអវត្តមាន
- ការអានវិញ្ញាបនប័ត្រពេទ្យ
- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- សំណូមពររបស់ជនជាប់ចោទ
- ពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

[redacted]

**តុលាការ ខេត្តបាត់ដំបង**

**យល់ឃើញថា**

- ឆ្លងតាមរយៈសវនាការនេះពុំមានភស្តុតាងច្បាស់លាស់អាចអោយតុលាការកំណត់បានថាជនជាប់ចោទឈ្មោះ [redacted] ណារ៉ុំ . [redacted] រ៉ា . [redacted] ទេវី . [redacted] ឌី និង [redacted] ជាស៊ី ហៅ ពៅ បានប្រព្រឹត្តអំពើជេរប្រមាថ-ដូចមានចែងនៅក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឡើយ ដូច្នេះផ្អែកតាមមាត្រា ៣៨ វាក្យខ័ណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គប្បីតុលាការសំរេចអោយជនជាប់ចោទទាំង ៥ នាក់ខាងលើនេះ-រួចផុតពីបទចោទ ។

- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់អាចអោយតុលាការកំណត់បានថាជនជាប់ចោទឈ្មោះ- [redacted] ណារ៉ុំ . [redacted] រ៉ា . [redacted] ទេវី . [redacted] ឌី [redacted] ជាស៊ី ហៅ ពៅ បានប្រព្រឹត្តអំពើបង្ករបួសស្នាមដោយចេតនាមានអាវុធ រីឯជនជាប់ចោទ [redacted] វណ្ណា . [redacted] ប៊ុ . [redacted] រ៉ហ៊ី . [redacted] ឈាន ក្រៅពីប្រព្រឹត្តបទល្មើសបង្ករបួសដោយចេតនាមានអាវុធនៅបានប្រើពាក្យជេរប្រមាថផ្លាដែលបំពានលើមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទៀតផង ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទទាំងនេះ តាមមាត្រាច្បាប់ដែលពួកគេម្នាក់ៗបានបំពាន ។

- ការប្តឹងទាមទារសំណង[illegible]រដ្ឋប្បវេណី [redacted] ណារ៉ុំ . [redacted] ជាស៊ី . [redacted] វណ្ណា . [redacted] [illegible]បានច្បាស់លាស់ ពុំអាចអោយតុលាការលើកទៅ និង [redacted] សុខា ពុំមានភស្តុតាងប[illegible] [redacted] ឌី ដែលមានភស្តុតាងបញ្ជាក់ពីការរបួស-យកមកពិចារណាបានទេ លើកលែងតែការ[illegible]របស់[illegible]

[redacted]



Scanned with CamScanner

ស្នាមពិតប្រាកដ ដែលបង្កឡើងដោយជនជាប់ចោទ [redacted] ភ៊ា . [redacted]រ៉ហ៊ិន និង [redacted]រ៉ហ៊ី តប្បីតុលាការពិចារណា និងសំរេច ។

- ជនជាប់ចោទភាគច្រើនទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ពុំមានពិការភាពធ្ងន់ធ្ងរ ...ប្រព្រឹត្តបទល្មើសជាលើកដំបូង តប្បីតុលាការលើកយកទោសព្យួរមកអនុវត្ត–លើកលែងតែ ស៊ុម ភ៊ា ម្នាក់គត់ដែលប្រព្រឹត្តបទល្មើសក្នុងរយៈពេលសាកល្បងពុំអាចអោយតុលាការព្យួរទោសបានឡើយ ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការត្រឹមត្រូវទៅតាមទម្រង់ និងគតិច្បាប់ លើកលែងតែការតម្កល់បទចោទលើ [redacted] ណារ៉ូ . [redacted]ភ៊ា . [redacted] ទេវី . [redacted]ឌី និង[redacted] ជាស៊ី ពីបទជួញដូរប្រ-មាថដែលគប្បីតុលាការសំរេចអោយរួចពីបទចោទព្រោះគ្មានភស្តុតាងគ្រប់គ្រាន់ ។

- ជនជាប់ចោទ [redacted] ណារ៉ូ [redacted]វណ្ណា . [redacted] ជាស៊ី . [redacted] ទេវី . [redacted] ប៊ូ និង[redacted]ឌី សុទ្ធតែសំណូមពរសុំអោយតុលាការលើកលែងទោស តែតុលាការពុំអាចលើកលែងទោសបានទេ ។

**ហេតុដូច្នេះ**

**<u>សំរេច</u>**

១/- អោយជនជាប់ចោទឈ្មោះ

ក- [redacted] ណារ៉ូ ភេទប្រុស អាយុ ៤៦ ឆ្នាំ សញ្ជាតិខ្មែរ ។

ខ- [redacted] ភ៊ា ភេទស្រី អាយុ ៤១ ឆ្នាំ សញ្ជាតិខ្មែរ ។

គ- [redacted] ទេវី ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ ។

ឃ- [redacted] ឌី ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ ។

ង- [redacted] ជាស៊ី ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ សញ្ជាតិខ្មែរ ។

រួចផុតពីបទជួញប្រមាថប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៨៦ ដសសព ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង និងតាមដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១០៣២ ពស-ព្រម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តបាត់ដំបង ។

តាមមាត្រា ៣៨ វាក្យខ័ណ្ឌទី ៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

២/- ផ្តន្ទាទោសលើជនជាប់ចោទ :

ក- [redacted] ភ៊ា ភេទស្រី អាយុ ៤១ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ ខែ ( បីខែគត់ ) និងកែប្រែទោសព្យួរ ១០ ខែ ( ដប់ខែ ) តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤០ "ច" ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០៤ របស់តុលាការខេត្តបាត់ដំបងទៅជាទោសដាក់ពន្ធនាគារ ។

សរុបទោស គឺដាក់ពន្ធនាគារសរុប ១៣ ខែ ( ដប់បីខែគត់ ) គិតពីថ្ងៃទទួលរងទោសក្នុងពន្ធនា-គារ ។

ខ- [redacted] ណារ៉ូ ភេទប្រុស អាយុ ៤៦ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៦ ខែ( ប្រាំមួយខែ-គត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។

គ- [redacted] ទេវី ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ ខែ( បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ឃ- [redacted] ឌី ភេទស្រី អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ ខែ ( បីខែគត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ង- [redacted] ជាស៊ី ហៅ ពៅ ភេទស្រី អាយុ ៣២ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ ខែ ( បួនខែគត់ ) ប៉ុន្តែទោសនេះត្រូវព្យួរ ។



Scanned with CamScanner

រយៈពេលសាកល្បង ៥ ឆ្នាំគត់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ពីបទបង្ករបួសដោយចេតនាមានអាវុធ ។

៣/- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ

ក- [redacted] វណ្ណា ហៅ សេក ភេទប្រុស អាយុ ៣៥ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារសរុប ៦ ខែ (ប្រាំមួយខែគត់) ។ ប៉ុន្តែទោសនេះត្រូវព្យួរ ។

ខ- [redacted] ប៊ូ ភេទប្រុស អាយុ ១៧ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ ខែ (បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

គ- [redacted]រ៉ហ៊ី ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារកំណត់៤ ខែ(បួនខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

ឃ- [redacted] ឈាន ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់ ៣ ខែ(បីខែគត់)ប៉ុន្តែទោសនេះត្រូវព្យួរ ។

ង- [redacted]ហ៊ីន ភេទស្រី អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរឥស្លាម ។ ដាក់ពន្ធនាគារសរុប ៣ ខែ (បីខែគត់) ប៉ុន្តែទោសនេះត្រូវព្យួរ ។

រយៈពេលសាកល្បង ៥ ឆ្នាំគត់គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ពីបទបង្ករបួសដោយចេតនាមានអាវុធ និងជេរប្រមាថប្រព្រឹត្តនៅភូមិចំការសំរោង១ ឃុំចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៤ ។

បទល្មើសច្បាប់ព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា ៤១ និង ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋ ។

៤/- បង្គាប់អោយជនជាប់ចោទឈ្មោះ [redacted] ភ៉ា [redacted]ហ៊ីន និង[redacted]ហ៊ី រួមគ្នាសងថ្លៃព្យាបាលរបួស និងជម្ងឺចិត្តសរុប ២.០០០.០០០៛០០ (ពីរលានរៀលគត់) ទៅអោយនាង[redacted]ទី សំណូមពរលើសពីនេះត្រូវបដិសេធចោល ។

៥/- ពេលសាលក្រមចូលជាស្ថាពរ បើជនជាប់ចោទឈ្មោះ [redacted] ភ៉ា [redacted] រ៉ហ៊ីន និង[redacted]ហ៊ី រឹងរូសពុំព្រមបង់ប្រាក់សំណងចំនួន ២.០០០.០០០៛០០ ទៅអោយដើមបណ្តឹងឈ្មោះ [redacted]ទី ទេនោះ ត្រូវដាក់គុកបង្ខំដល់រូបរាងកាយក្នុងម្នាក់១ពីរឆ្នាំ ដើម្បីបង្ខំទារប្រាក់ធនក័ណ្ឌតាមមាត្រា ៧ និង ៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបរាងកាយក្នុងរឿងព្រហ្មទ័ណ្ឌ ។

៦/- សាលក្រមនេះជំនុំជំរះចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ណារ៉ូ . [redacted] វណ្ណា . [redacted] ជាស៊ី [redacted] ទៅ . [redacted] ប៊ូ . [redacted] ទី កំបាំងមុខជនជាប់ចោទ[redacted] ភ៉ា . [redacted] រ៉ហ៊ីន . [redacted]ហ៊ី និង [redacted] ឈាន ។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និង ត្រា : មូ សមូស្ស

ចៅក្រមជំនុំជំរះ
ហត្ថលេខា និងត្រា : អ៊ុត សមូស្ស

បានវាយចម្លងត្រឹមត្រូវតាមសាលក្រមដើម
បាត់ដំបង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧
ក្រឡាបញ្ជី
[redacted]

បានឃើញ
បាត់ដំបង ,ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧
ចៅក្រម
[redacted]



Scanned with CamScanner